ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៤ លេខ២ | មេសា - មិថុនា ឆ្នាំ២០១០ | តម្លៃ ១.៥០០៛

20 ខួបលើកទី
CDRI 1990-2010

## "ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ-អាទិភាពខាងគោលនយោបាយ និង សកម្មភាព ដើម្បីកំណើន និងការអភិវឌ្ឍមានចីរភាព" ៖ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី ៤ [១]

### សេចក្តីផ្តើម

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា លើកទី៤ លើប្រធានបទ "ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ" បានប្រារព្ធឡើងនៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី ១៧ មីនា ២០១០ ក្រោមកិច្ចសហការជាដៃគូរវាង វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង ធនាគារ ANZ Royal ។ ជាថ្មីម្តងទៀត សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់តាមការអញ្ជើញចូលរួម ជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះក្នុងពិធីបើកសន្និសីទ ជូនដល់ភ្ញៀវកិត្តិយសជាង ៣៥០នាក់ ជាថ្នាក់ដឹកនាំមកពីជួររដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ។



សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កំពុងទស្សនាផ្ទាំងរូបភាពស្តីពីប្រវត្តិរបស់ វិទ្យាស្ថាន CDRI ក្នុងរយៈពេល ២០ឆ្នាំ ដែលដាក់តាំងបង្ហាញនៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០

ក្នុងពេលថ្លែងសុន្ទរកថា សម្តេចនាយករដ្ឋមន្ត្រីបានបញ្ជាក់ថា "សន្និសីទរបស់យើងឆ្នាំនេះមានសារៈសំខាន់ណាស់ ដោយសារឆ្នាំនេះ ជាខួបលើកទី ២០ នៃការបង្កើតវិទ្យាស្ថាន CDRI ដែលជាអ្នករៀបចំសន្និសីទនៅថ្ងៃនេះ និងជាស្ថាប័នស្រាវជ្រាវកម្ពុជា ឯករាជ្យឈានមុខខាងគោលនយោបាយអភិវឌ្ឍន៍ ។ វិទ្យាស្ថាន CDRI បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់អនុសាសន៍ខាងគោលនយោបាយ ដែលផ្អែកលើការស្រាវជ្រាវ និងភស្តុតាងច្បាស់លាស់ ជូនរាជរដ្ឋាភិបាល និងភាគីផ្សេងទៀតដែលពាក់ព័ន្ធក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ។ ...ប្រទេសកម្ពុជាបានរីកលូតលាស់ អភិវឌ្ឍ និងផ្លាស់ប្តូរយ៉ាងច្រើនក្នុង ២០ឆ្នាំកន្លងមកនេះ ហើយវិទ្យាស្ថាន CDRI ក៏បានរីកលូតលាស់ អភិវឌ្ឍ និងផ្លាស់ប្តូរទៅមុខ ដូចគ្នា ប៉ុន្តែបានអនុវត្តអាណត្តិរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ពោលគឺ ធ្វើការស្រាវជ្រាវខាងគោលនយោបាយប្រកបដោយឯករាជ្យ និងគុណភាព ធ្វើការបណ្តុះបណ្តាល និងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងសមត្ថភាពផ្សេងៗទៀតរបស់ប្រជាជនកម្ពុជា និងចូលរួមចំណែកផ្នែកបញ្ញាញាណយ៉ាងធំធេងដល់ប្រទេសជាតិ" ។

សន្និសីទនេះ ផ្តោតលើកត្តាសំខាន់ៗ ដែលអាចជួយឲ្យកម្ពុជាសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ និងមានចីរភាព ព្រមទាំងការកាត់បន្ថយភាពក្រីក្រ ទាំងក្នុងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម អភិវឌ្ឍន៍ជនបទ ឧស្សាហកម្មទើបផុសឡើង ហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងទេសចរណ៍ ។ សន្និសីទនេះបានរកឃើញថា សំរាប់កម្ពុជា កំណើនសេដ្ឋកិច្ចក្នុងកំរិតខ្ពស់ប្រកបដោយចីរភាព ត្រូវផ្អែកលើបរិយាកាស

តទៅទំព័រ ២៣

## មាតិកា

ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ
សូចនាករ ការរំពឹងទុក និងអាទិភាព ........................ ២
ជំរុញការនាំចេញមាសសរបស់កម្ពុជា .................................. ៦
ការពង្រឹងវិស័យសំខាន់ៗដើម្បីសំរេចបានកំណើន
សេដ្ឋកិច្ចខ្ពស់ឡើងវិញ ................................................ ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស................ ១៥
— ស្ថានភាពក្នុងប្រទេស ............... ១៧
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ...................................... ២៤

១ Larry Strange នាយកប្រតិបត្តិ នៃវិទ្យាស្ថាន CDRI ណែនាំបង្ហាញពីសិន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ នៅក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក្នុងលេខពិសេសនេះ ។

# ការសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ សូចនាករ ការរំពឹងទុក និង អាទិភាពខាងគោលនយោបាយ

អត្ថបទនេះ ជាសេចក្ដីសង្ខេបនៃបទបង្ហាញរបស់លោក John Nelmes[១] ឯកឧត្តម បណ្ឌិត ហង់ ជួនណារ៉ុន[២] និងលោក Stephane Guimbert[៣] ។ អត្ថបទនេះ លើកពីសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ការរំពឹងទុកសម្រាប់អនាគត និងជម្រើសជាគោលនយោបាយមួយចំនួន ដើម្បីសំរេចបានកំណើនប្រកបដោយចីរភាព ដែលនឹងជួយឲ្យមានការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើនៗ និងជាបន្តក្នុងទូទាំងប្រទេស ។

លោក Nelmes បានធ្វើបទបង្ហាញលើប្រធានបទធំៗមួយចំនួនដូចតទៅ៖

- សេដ្ឋកិច្ចសាកល៖ ការរើបឡើងក្នុងពហុល្បឿន
- សូចនាករនាពេលថ្មីៗរបស់កម្ពុជា៖ តើយើងដើរដល់ណាហើយ?
- ការរំពឹងទុក និងជម្រើសគោលនយោបាយ៖ តើយើងកំពុងដើរទៅណា និងត្រូវជ្រើសយកផ្លូវណា?

ទាក់ទងនឹងសេដ្ឋកិច្ចសាកល លោក Nelmes បានលើកឡើងថា បន្ទាប់ពីបានធ្លាក់ចុះយ៉ាងខ្លាំង សេដ្ឋកិច្ចសាកលកំពុងរើបឡើងវិញ ហើយពាណិជ្ជកម្មក៏ស្ទុះឡើងដែរ ។ ការរើបឡើងជាសាកល បានចាប់ផ្ដើមឡើងខ្លាំងក្លាជាងការរំពឹងទុក ទោះបីវាមានសន្ទុះខុសៗគ្នាទៅតាមតំបន់ក្ដី ។ លោកបានបញ្ជាក់ថា បើគិតតាមតំបន់ ទ្វីបអាស៊ីនាំមុខគេក្នុងការរើបឡើងវិញនេះ ដោយសារតម្រូវការក្នុងស្រុកមានច្រើន និងការបើកចំហចំពោះពាណិជ្ជកម្មដែលកំពុងរើបឡើង ។ ការរើបឡើងវិញជាសាកលនេះ មានការទ្រទ្រង់ពីការបន្ធូរបន្ថយយ៉ាងខ្លាំងបំផុត នូវគោលនយោបាយខាងសារពើពន្ធ និងរូបិយវត្ថុ ។ ខាងប៉ែកបណ្ដាប្រទេសសេដ្ឋកិច្ចជឿនលឿន ពួកគេបានឆ្លងផុតការធ្លាក់ចុះសេដ្ឋកិច្ច ប៉ុន្ដែកំណើន ផសស នៅទាបជាខ្លាំងបើធៀបមុនពេលមានវិបត្តិ ។ ម្យ៉ាងទៀត ការរើបសេដ្ឋកិច្ចនេះរំពឹងថានឹងមានសន្ទុះយឺត បើធៀបនឹងល្បឿនធម្មតាកាលពីមុន ដោយសារភាពអត់ការងារធ្វើមានកំរិតខ្ពស់ កំណើនឥណទាននៅខ្សោយដោយហេតុ ធនាគារកំពុងរវល់ជួសជុលតារាងតុល្យការរបស់ខ្លួន និងបំណុលសាធារណៈកំរិតខ្ពស់ ។ លោកបានបង្ហាញថា អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានជួយទ្រទ្រង់ដល់បណ្ដាប្រទេសជាសមាជិករបស់ខ្លួននៅអំឡុងពេលមានវិបត្តិ ដោយផ្ដល់ជំនួយគាំទ្រហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

សម្រាប់ប្រទេសកម្ពុជា លោកបានបង្ហាញថា សេដ្ឋកិច្ចមានលក្ខណៈវិជ្ជមានជាងកាលពីមុន ក្នុងនេះ (ក) ការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចមានកំរិតខ្ពស់នៅឆ្នាំ២០០៩ ប៉ុន្ដែវិស័យកសិកម្មមានស្ថានភាពល្អ (ខ) សេដ្ឋកិច្ចទំនងជាបានធ្លាក់ចុះដល់កំរិតទាបបំផុតតាំងពីចុងឆ្នាំមុន ហើយឥឡូវនេះកំពុងរើបឡើងវិញ (គ) កំណើនក្នុងឆ្នាំ២០០៩ គឺ -២.៥% ដែលមិនធ្ងន់ធ្ងរដូចការព្យាករណ៍កាលពីមុនរបស់ IMF នោះទេ និង (ឃ) អតិផរណាបានធ្លាក់ចុះយ៉ាងច្រើន ។

សម្រាប់ផលប៉ះពាល់តាមវិស័យ និងអនុវិស័យ លោក Nelmes បានលើកពាក់ព័ន្ធដល់វិស័យមួយចំនួន ដូចជា កាត់ដេរ ទេសចរណ៍ សំណង់ កសិកម្ម ព្រមទាំង ហិរញ្ញវត្ថុផងដែរ ។ វិស័យកាត់ដេរ មានការប៉ះពាល់ធ្ងន់ធ្ងរ ដោយសារតម្រូវការនៅសហរដ្ឋអាមេរិកធ្លាក់ចុះ ប៉ុន្ដែការរើបសេដ្ឋកិច្ចអាមេរិក អាចជួយឲ្យវាមានកំណើនវិញ ។ ទោះយ៉ាងនេះក្ដី ការប្រកួតប្រជែងខ្លាំងក្លាក្នុងតំបន់ អាចចោទបញ្ហាដល់ការរើបឡើងនៃវិស័យកាត់ដេរ ។ សម្រាប់វិស័យទេសចរណ៍ ចំនួនភ្ញៀវមកដល់កំពុងកើនឡើងវិញ ប៉ុន្ដែពួកគេចំណាយលុយតិចជាខ្លាំងជាងឆ្នាំមុន ។ ការធ្លាក់ចុះប្រាក់ចំណូលពីវិស័យទេសចរណ៍ អាចបណ្ដាលជាសំខាន់មកពីការផ្លាស់ប្ដូរប្រភព ពោលគឺ ប្រទេសដើមរបស់ភ្ញៀវទេសចរ ។ នាបច្ចុប្បន្ន ភ្ញៀវទេសចរមកពីប្រទេសជិតខាងបានកើនឡើង ប៉ុន្ដែអំណាចទិញរបស់ពួកគេមានកំរិត ហើយចំនួនភ្ញៀវទេសចរពីបណ្ដាប្រទេសអ្នកមានបានធ្លាក់ចុះវិញ ។

នៅកំរិតម៉ាក្រូ អនុមតិគំរោងវិនិយោគបានធ្លាក់ចុះជាខ្លាំង ប៉ុន្ដែការផ្លាស់ប្ដូរក្នុងប្រភេទគំរោងវិនិយោគ គឺជាសញ្ញាល្អសម្រាប់កំណើនក្នុងរយៈពេលវែង ។ សកម្មភាពសាងសង់រើបឡើងយឺតៗ បន្ទាប់ពីបានធ្លាក់ចុះធ្ងន់ធ្ងរ រីឯជំនួញលក់រាយ ក៏កើនឡើងដែរ ។ ការផ្ដល់ឥណទានកើនឡើងបន្ដិចវិញ បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុក ដោយសារពីមុនរីកដុះដាលលឿនហួសពេក ។ អតិផរណាធ្លាក់ចុះយ៉ាងខ្លាំង ស្របគ្នានឹងការរួមចុះតម្រូវការ ប៉ុន្ដែការឡើងថ្លៃផលិតផល និងការបង្កើនថវិកាចំណាយសាធារណៈនាពេលថ្មីៗបានដាក់សំពាធធ្វើឱ្យវាកើនឡើងវិញ ។

វិស័យកសិកម្មនៅតែមានស្ថានភាពល្អ ដោយសារមួយផ្នែកគឺកំណើនផលិតភាព និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ ប៉ុន្ដែកំណើនក្នុងវិស័យនេះ មិនធំគ្រប់គ្រាន់សំរាប់ប៉ះប៉ូវការធ្លាក់ចុះក្នុងវិស័យឯទៀតៗនោះទេ ។ ការផ្លាស់ប្ដូរទាំងអស់ ដែលកើតមានកន្លងមក ធ្វើឲ្យគេរំពឹងថា កំណើន GDP សរុបក្នុងឆ្នាំ២០០៩ មានអត្រាប្រមាណជា - ២.៥% ។ ទោះបីវិស័យកសិកម្ម និងចំណាយសាធារណៈបានកើនឡើងក្ដី ប៉ុន្ដែវិស័យគន្លឹះៗមួយចំនួនបានរួមចុះ ហើយនាំឱ្យមានការធ្លាក់ចុះជារួមក្នុងសកម្មភាពសេដ្ឋកិច្ច ។

សម្រាប់ការរំពឹងទុក និងជម្រើសគោលនយោបាយ លោក Nelmes បានលើកថា (ក) កំណើននឹងមានអត្រាប៉ាន់ស្មានវិជ្ជមានវិញ ដល់ប្រហែល ៤% ក្នុងឆ្នាំ២០១០ ដោយសារការរើបឡើងវិញនៃសេដ្ឋកិច្ចសាកល (ខ) ការពង្រឹងផ្នែកសារពើពន្ធបានសមស្រប ជាកត្តាគន្លឹះសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (គ) ការរក្សាការពារសកម្មភាពប្រព័ន្ធហិរញ្ញវត្ថុ ជួយបង្កើនលទ្ធភាពទទួល

---

១ តំណាងនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រចាំប្រទេសកម្ពុជា ។

២ រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានអចិន្ត្រៃយ៍ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI ។

៣ សេដ្ឋវិទូជាន់ខ្ពស់នៃធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា ។

បានហិរញ្ញប្បទាន និង (ឃ) កំណែទម្រង់រចនាសម្ព័ន្ធកាន់តែស៊ីជម្រៅ អាចជួយបង្កើនសក្ដានុពល មានកំណើនក្នុងរយៈពេលវែង ។

លោក Nelmes បានអះអាងពីការរំពឹងទុកថា កំណើនអាចស្ទុះឡើងថែមទៀតរហូតដល់ជាង ៤% នៅឆ្នាំ២០១០ ប្រសិនបើវិស័យកសិកម្មនៅតែមានកំណើនថេរ ស្ថានភាពក្នុងសាកលលោកប្រែប្រួលប្រសើរឡើងទៀត ហើយ តម្រូវការក្នុងស្រុកក៏រើបឡើងវិញ ។ ឱនភាពថវិកាដែលធូរស្រាលឡើង ក៏ជាកត្តាមួយជួយដល់សេដ្ឋកិច្ចដែរ ។ ឱនភាពថវិកាឆ្នាំ២០១០ រំពឹងថាមានកំរិត ៥.២៥% នៃ ផសស ហើយលោកបានវែកញែកថា ឱនភាពកំរិតទាបជាងនេះអាចសមស្របល្អ ប៉ុន្ដែគួរជៀសវាងការប្រើហិរញ្ញប្បទាន អំពីប្រព័ន្ធធនាគារក្នុងស្រុក ។ លោកបានលើកសរសើរលទ្ធផលប្រមូលប្រាក់ចំណូលរបស់រាជរដ្ឋាភិបាលនៃកម្ពុជាក្នុងឆ្នាំ២០០៩ ហើយបានអះអាងថា កិច្ចប្រឹងប្រែងជាបន្ដក្នុងឆ្នាំ២០១០ អាចលុបបំបាត់តម្រូវការប្រើហិរញ្ញប្បទានក្នុងស្រុក និងបើកឱកាសសម្រាប់ការបង្កើនចំណាយអភិវឌ្ឍន៍ជាអាទិភាពច្រើនថែមទៀត ។

ទាក់ទិននឹងវិស័យហិរញ្ញវត្ថុ និងធនាគារ លោក Nelmes បានជជែកវែកញែកឲ្យមានការត្រួតពិនិត្យខ្លាំងជាបន្ដទៀត លើវិស័យធនាគារ និងការពង្រឹងអនុវត្តវិធានប្រុងប្រយ័ត្ន ដើម្បីធានាស្ថិរភាព និងជួយសម្រួលបង្កើនលទ្ធភាពទទួលបានហិញ្ញប្បទាន ។ លោកបានចង្អុលបង្ហាញថា ប្រព័ន្ធធនាគារបច្ចុប្បន្ន មានប្រើសាច់ប្រាក់ច្រើនណាស់ ប៉ុន្ដែប្រាក់ចំណេញមានតិច ដោយសារអប្បហារអត្រាការប្រាក់អវិជ្ជមាន ។ លោកបានដាស់តឿនដល់អាជ្ញាធរខាងវិស័យធនាគារ ឱ្យជៀសវាងកំណើនច្រើនៗដូចមុនទៀតនៃការផ្ដល់កំចីដើម្បីកាត់បន្ថយហានិភ័យនៃការដួលរលំតាមក្រោយ ។

សម្រាប់រយៈពេលវែង លោក Nelmes ផ្ដល់មតិថា កំណើនរឹងមាំមានចីរភាព អាចជួយឲ្យកម្ពុជាឡើងឋានៈជាប្រទេសមានចំណូលមធ្យម ។ ប៉ុន្ដែដើម្បីធានាឲ្យកំណើនមានចីរភាព ត្រូវប្រឹងប្រែងបង្កើនគុណភាពហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពធនធានមនុស្ស ដែលជាកត្តាមូលដ្ឋានសំរាប់ការឡើងឋានៈនៅក្នុងអាស៊ាន ។ ដើម្បីមានកំណើនលឿនជាងប្រទេសជិតខាងក្នុងរយៈពេលវែង ត្រូវមានយុទ្ធសាស្ដ្រធំទូលាយ បង្កើនសមត្ថភាពប្រកួតប្រជែង ។ ដើម្បីសម្រេចគោលដៅនេះ IMF បានជួយដល់រាជរដ្ឋាភិបាលក្នុងវិស័យមួយចំនួន ដូចជា៖

- ការផ្ដល់មតិប្រឹក្សាលើគោលនយោបាយ សម្រាប់វិស័យហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ក្រោមការពិនិត្យតាមដានរបស់ IMF
- ជំនួយបច្ចេកទេស ដូចជា
  - ឧបករណ៍ និងក្របខណ្ឌ សម្រាប់គោលនយោបាយរូបិយវត្ថុ
  - ការពង្រឹងការពិនិត្យតាមដានក្នុងវិស័យធនាគារ
  - កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  - វគ្គបណ្ដុះបណ្ដាលជំនាញឯកទេស ក្នុងការបង្កើតគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដើម្បីកសាងសមត្ថភាពធនធានមនុស្ស ។

បណ្ឌិត ហង់ ជួន ណារ៉ុន បានធ្វើបទបង្ហាញជាបន្ត ដោយបានបកស្រាយលើគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍសេដ្ឋកិច្ច ដូចជា ការផ្ដល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច គោលនយោបាយជាអាទិភាព សម្រាប់កំណើន ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍវិស័យឯកជន និងការគ្រប់គ្រងធនធានធម្មជាតិ ។ អត្ថបទនេះ មានបង្ហាញដោយសង្ខេបពីបញ្ហាផ្សេងៗ ទាក់ទងនឹងគោលនយោបាយជាអាទិភាព សម្រាប់កំណើនការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ។

ជាបឋម បណ្ឌិត ណារ៉ុន បានបូកសរុបពីសក្ដានុពលកំណើនរបស់កម្ពុជា ដែលមានជាអាទិ៍៖

- ដីអាចដាំដុះដ៏សំបូរ ដែលជាសក្ដានុពលសម្រាប់ការអភិវឌ្ឍ និងពិពិធកម្ម ផលិតកម្មកសិកម្ម ដូចជា ការកែច្នៃកសិផលជាដើម ។ កំណើនផលិតកម្ម ជាពិសេសផលិតកម្មផលដំណាំសំខាន់ៗ ដូចជា ស្រូវ អាចបំរើដល់ការនាំចេញ ។ គោលនយោបាយរបស់សហភាពអឺរ៉ុប (EU) ស្ដីពី "អ្វីទាំងអស់ក្រៅពីអាវុធ" ក៏ដូចជាការនាំចេញស្រូវដោយមិនជាប់ពន្ធទៅបណ្ដាប្រទេស EU បានផ្ដល់ទីផ្សារមានចំណេញច្រើនដល់កម្ពុជា ។ ប៉ុន្ដែដើម្បីសំរេចសក្ដានុពលនេះបាន ត្រូវដោះស្រាយកត្តារាំងស្ទះផលិតកម្មកសិកម្ម និងត្រូវផ្ដល់អាទិភាពដល់ការវិនិយោគបន្ថែមលើធារាសាស្ដ្រ និងការផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសនៅតំបន់ជនបទ ។
- ពលកម្មតម្លៃថោកនៅសំបូរច្រើន តែមានជំនាញទាប ។ ដូចក្នុងផ្នែកកាត់ដេរដែរ គេអាចប្រើប្រាស់អតិរេកពលកម្មក្នុងផលិតកម្មឧស្សាហកម្មមួយចំនួន ។ ប៉ុន្ដែក្នុងរយៈពេលវែង គួរយកចិត្តទុកដាក់ ជាពិសេសលើការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រសិនបើកម្ពុជាចង់សំរេចបានកំណើនប្រកបដោយចីរភាព និងបានដល់គ្រប់ៗគ្នា ដើម្បីអាចដើរទាន់បណ្ដាប្រទេសជិតខាងខ្លួន ។
- កេរ្ដិ៍ដំណែលវប្បធម៌ និងជីវចំរុះធម្មជាតិដ៏សំបូរ ដែលផ្ដល់ឱកាសល្អ សម្រាប់ការពង្រីងវិស័យទេសចរណ៍ និងទទួលផលចំណេញបានកាន់តែច្រើនពីទេសចរណ៍អន្ដរជាតិ ។
- ធនធានរ៉ែ ប្រេងកាត និងឧស្ម័ន មិនទាន់បានទាញយកផល និងប្រើប្រាស់យ៉ាងសក្ដិសិទ្ធិ ដើម្បីបង្កើតប្រាក់ចំណូលដែលកំពុងមានតម្រូវការជាខ្លាំង សម្រាប់ការអភិវឌ្ឍប្រទេសទៅតាមបទពិសោធន៍របស់ប្រទេសមួយចំនួនដែលបានអភិវឌ្ឍលឿននៅក្នុងតំបន់ ។

លោក ណារ៉ុន បានលើកនូវគោលនយោបាយប្រាំមួយមុខព្រួញ សម្រាប់ធ្វើឲ្យសក្ដានុពលកំណើនក្លាយជាការពិត គឺមាន ១- ការអភិវឌ្ឍធនធានមនុស្ស ២- ការអភិវឌ្ឍកសិកម្ម ៣- ទេសចរណ៍ (ចាប់ពីទេសចរណ៍វប្បធម៌ទៅដល់ទេសចរណ៍ឆ្នេរសមុទ្រ) ៤- ហេដ្ឋារចនាសម្ព័ន្ធ (ទាំងផ្នែកក្របខ័ណ្ឌច្បាប់ និងផ្នែករូបវន្ដ) ៥- ឧស្សាហកម្មកំពុងផុសឡើង និង ៦- ឧស្សាហកម្មកែច្នៃ ។ ដើម្បីអនុវត្តគោលនយោបាយនេះ ត្រូវមានអាទិភាពមួយចំនួននៅកំរិតម៉ាក្រូ/ហិរញ្ញវត្ថុ កំរិតហិរញ្ញវត្ថុ ក៏ដូចជា កំរិតសហគ្រាស ។

នៅកំរិតម៉ាក្រូ/ហិរញ្ញវត្ថុ ត្រូវផ្ដល់អាទិភាពដល់ការធ្វើឱ្យមានកំណើនឡើងវិញ ព្រមទាំងការរក្សាស្ថិរភាព ។ ការធ្វើឱ្យមានកំណើនឡើងវិញ អាចសំរេចបានតាមការគួបផ្សំគ្រឿងជំរុញខាងហិរញ្ញវត្ថុ គោលនយោបាយរូបិយវត្ថុ និងការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ ។

នៅកំរិតនេះ គោលនយោបាយគួរសំដៅជួយបង្កើនភាពប្រកួតប្រជែង (តួនាទីជាគោលនយោបាយអត្រាការប្រាក់ នៃគោលនយោបាយពន្ធដា) និងការកៀងគរប្រាក់សន្សំក្នុងស្រុក ។

នៅកំរិតហិរញ្ញវត្ថុ គោលនយោបាយគួរផ្តោតលើការបង្កើតឱកាសហិរញ្ញវត្ថុថ្មីៗ (ពន្ធ និងមិនមែនពន្ធ ព្រមទាំងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)) ។ ការចំណាយ គួរផ្តោតលើកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ (ការថែទាំ ជួសជុល) និងការអប់រំ ។ មានបញ្ហាជាច្រើនជាប់ទាក់ទងនឹងគុណភាពនៃការចំណាយ និងប្រព័ន្ធសុវត្ថិភាពសង្គម ដែលគួរគិតគូរពិចារណាយ៉ាងប្រយ័ត្នប្រយែង ។ ម្យ៉ាងទៀត ក៏គួរមានកំណែទម្រង់រដ្ឋបាលសាធារណៈ សម្រាប់ការលើកកម្ពស់សមត្ថភាពអនុវត្តដែរ ។

នៅកំរិតសហគ្រាស កំណែទម្រង់ខាងច្បាប់ និងការសម្របសម្រួលពាណិជ្ជកម្ម (ជាពិសេសក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជិតខាង) ក៏គួរផ្តល់អាទិភាពខ្ពស់ដែរ ។ នៅកំរិតគោលនយោបាយ គួរប្រុងប្រែង ធ្វើឲ្យគោលនយោបាយឧស្សាហកម្មអាចអនុវត្តបាន ។ ដើម្បីសំរេចរឿងនេះ គួរតាមដាន និងវាយតម្លៃលើគោលនយោបាយដែលបានដាក់អនុវត្ត (ឧ. ដូចជា SEZs, ELCs, ជាដើម) និងដាក់អនុវត្តឧបករណ៍ថ្មីៗទៀត (ឧ. កន្លែងផាត់ទាត់សម្រាប់វិនិយោគិនខាងកសិពាណិជ្ជកម្ម កំរិតស្តង់ដារផ្សេងៗ ការសំរបសំរួលតាមវិស័យជាដើម) ។ វិស័យផ្សេងទៀត ដែលគួរត្រួតពិនិត្យ និងតាមដានឲ្យជិតដល់ រួមមាន តួនាទី និងលក្ខណៈនៃវិនិយោគផ្ទាល់ពីបរទេស ក៏ដូចជាការជួបពិភាក្សារវាងវិស័យសាធារណៈ-ឯកជន (ឧ. វេទិកាវិស័យសាធារណៈ-ឯកជន) ។

បណ្ឌិត ណារ៉ុន បានលើកថា ពិពិធកម្មនៃសេដ្ឋកិច្ចកម្ពុជា ជាកត្តាគន្លឹះ សម្រាប់ពង្រឹកមូលដ្ឋានកំណើននៅក្នុងប្រទេស និងធានាឲ្យកំណើនមានចីរភាពល្អ ។ ក្រៅពីពិពិធកម្មដែលទន់ខ្សោយ ឬមានកំរិតការនាំចេញរបស់កម្ពុជា ក៏មិនសូវទំនើប (ឧទាហរណ៍ ខ្សែរយៈកំណត់តម្លៃបែបធម្មតាៗ) ហើយកម្ពុជា ក៏មិនមានស្ថានភាពល្អទេនៅលើទីផ្សារអន្តរជាតិ ។ លោកបណ្ឌិតអះអាងថា កម្ពុជាមានឧត្តមភាពប្រៀបធៀបជា ដីធ្លីដ៏សំបូរ ពលកម្មថោកក្នុងតំបន់ ហើយកត្តាទាំងនេះគួររក្សាឲ្យបាន ។ ពិពិធកម្មគួរសំរេចឲ្យបានក្នុងឧស្សាហកម្មដែលមានស្រាប់ ដូចជាតាមរយៈពិពិធកម្មក្នុងទីផ្សារ និងការបង្កើនសកម្មភាពពាណិជ្ជកម្មក្នុងតំបន់ ។ ការយកកសិពាណិជ្ជកម្មធ្វើជាមធ្យោបាយឈានទៅផលិតទំនិញថ្មីៗ ក៏គួរគិតគូរវាយតំលៃយ៉ាងប្រុងប្រយ័ត្នដែរ ។

ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ជាកត្តាគន្លឹះមួយទៀតនៃគោលនយោបាយ ដើម្បីសំរេចសក្តានុពលកំណើនរបស់កម្ពុជាឲ្យបាន ។ ដើម្បីអាចប្រកួតប្រជែងក្នុងពិភពលោកដែលកាន់តែបើកចំហ និងធ្វើសេរីភាវូបនីយកម្ម ត្រូវមានជាសំខាន់នូវធនធានមនុស្ស ។ រឿងនេះ អាចសំរេចបានតាមរយៈ ការបង្កើតវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ។ ដោយសារមានពិពិធកម្មឧស្សាហកម្ម ការងារមួយដែលកាន់តែសំខាន់ឡើង គឺត្រូវពង្រឹងយន្តការដោះស្រាយវិវាទការងារដែលមានស្រាប់ ដូចជា ក្រុមប្រឹក្សាមជ្ឈត្តកម្ម គណៈកម្មការដោះស្រាយកូដកម្មនៅគ្រប់កំរិត ការបណ្តុះបណ្តាលអ្នកសំរុះសំរួលស្ម័គ្រចិត្តក្នុងជួរអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយវិវាទការងារដោយសន្តិភាព និងធានាឲ្យការងារមានចីរភាព ។

តមកទៀត បណ្ឌិត ណារ៉ុន បានពិចារណាពីសក្តានុពលសម្រាប់កំណើនវិស័យកសិកម្ម ដែលអាចសំរេចបានតាមរយៈយុទ្ធសាស្ត្រវិស័យកសិកម្មមួយដ៏សក្តិសិទ្ធិ ។ លោកបានវែកញែកថា យុទ្ធសាស្ត្រនេះ ត្រូវមានរួមបញ្ចូលនូវសមាសធាតុដូចខាងក្រោម៖

- បង្កើនផលិតភាពកសិកម្ម តាមរយៈ
  - វិនិយោគលើសំណង់ធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទ
  - ការបង្កើនការប្រើប្រាស់ជី រីកសិកម្មសរីរាង្គ
  - ការបង្កើនការស្រាវជ្រាវ និងការផ្សព្វផ្សាយបច្ចេកទេស
  - ការបង្កើនលទ្ធភាពទទួលបានឥណទាន
- ការសំរបសំរួល និងការតភ្ជាប់កសិករកម្ពុជា ទៅនឹងខ្សែរយៈកំណត់តម្លៃម្ហូបអាហារសាកល
- គោលនយោបាយដើម្បីបង្កើនការនាំចេញកៅស៊ូ និងស្រូវ

ក្រាហ្វិក ១: ការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់ពិត



ក្រាហ្វិក ២: កត្តារាំងស្ទះដ៏ធ្ងន់ធ្ងរ (% នៃសហគ្រាសដែលបានរាយការណ៍ថាកត្តាទាំងនោះមានកំរិតធ្ងន់ធ្ងរ)




• ចង្កោមផលិតផលកសិកម្ម៖ ខ. វារីវប្បកម្មផ្សារភ្ជាប់ជាមួយការឧស្សាហកម្មផលិតចំណីត្រី និង ចំណីសត្វ ។

ពាក់ព័ន្ធនឹងប្រធានបទស្រដៀងគ្នានេះដែរ លោក Giumbert បានបង្ហាញដោយសង្ខេបនូវការសិក្សានាពេលថ្មីៗមួយ របស់ធនាគារពិភពលោក[៤] ស្តីពីកំណើនព្យាករណ៍សម្រាប់កម្ពុជា ។ ដំបូងលោកបានលើកពីចំណុចមួយ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដែលចែងថា "ក្នុងទិសដៅជានាក់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ដែលជាបុរេលក្ខខណ្ឌនៃការបង្កើតការងារ និងបង្កើនប្រាក់ចំណូលរបស់ប្រជាជន រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តវិធានការពិពិធភាវូបនីយកម្ម សេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា តាមរយៈការបង្កើតបរិស្ថានអនុគ្រោះដល់ការវិនិយោគ ទាំងវិស័យ សាធារណៈ ទាំងវិស័យឯកជន (ទាំងក្នុងស្រុក និងទាំងបរទេស) សម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ ដូចតទៅ៖ (១) កសិកម្ម (២) ទឹក និងប្រព័ន្ធធារាសាស្ត្រ (៣) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (៤) អគ្គិសនី (៥) ការអភិវឌ្ឍធនធានមនុស្ស (៦) ឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មផលិតទំនិញនាំចេញ (៧) ទេសចរណ៍ (៨) អាជីវកម្មប្រេងកាត ឧស្ម័នធម្មជាតិ និងរ៉ែដទៃទៀត (៩) បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ (១០) ពាណិជ្ជកម្ម (វាក្យខណ្ឌទី៤០ នៃយុទ្ធសាស្ត្រ ទំព័រ៣៨) ។ តទៅនេះ គឺជាសេចក្តីសង្ខេបនៃបញ្ហានានា ដែលលោកបានលើកមកវែកញែកទាក់ទងនឹងពាណិជ្ជកម្ម និងការសម្របសម្រួលពាណិជ្ជកម្ម ។

សម្រាប់ភាពប្រកួតប្រជែងខាងពាណិជ្ជកម្ម កត្តាគន្លឹះមួយចំនួន មានតួនាទីសំខាន់ ដូចជាការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់ពិតធៀបនឹងដៃគូប្រកួតប្រជែង ក៏ដូចជាកត្តារាំងស្ទះខាងទីផ្សារ ដែលពាណិជ្ជករកំពុងជួបប្រទះ ។ សម្រាប់ភាពប្រកួតប្រជែងខាងអត្រាប្តូរប្រាក់ ដូចមានបង្ហាញក្នុងក្រាហ្វិក១ នេះ កម្ពុជាបានបាត់បង់ភាពប្រកួតប្រជែងខ្លះហើយ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ រឿងនេះជាប់ទាក់ទងនឹងសេដ្ឋកិច្ចប្រើប្រាក់ដុល្លាររបស់កម្ពុជា និងការឡើងថ្លៃប្រាក់ដុល្លារក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយ ។

កត្តារាំងស្ទះសំខាន់ៗដល់កំណើន ភាពប្រកួតប្រជែង និងជាពិសេសពាណិជ្ជកម្ម បើតាមសេចក្តីសង្ខេបនៃការសិក្សាដែលបានលើកឡើង រួមមាន៖

- ការសម្របសម្រួលនៃខ្សែរយៈកំណត់តម្លៃ
- បទបញ្ញត្តិច្បាប់ស្មុគស្មាញ/ប្រាក់កំរៃក្រៅផ្លូវការ
- អគ្គិសនី
- ពាណិជ្ជកម្ម និងការផ្គត់ផ្គង់ឡូហ្ស៊ីស្ទិក

ដូចមានបង្ហាញក្នុងក្រាហ្វិក ២ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ទោះបីកត្តារាំងស្ទះភាគច្រើនហាក់ដូចបានថយចុះ ក្នុងនេះមានទាំងកត្តារាំងស្ទះដ៏ធ្ងន់ធ្ងរបំផុត ដែលជាប់ទាក់ទងនឹងអំពើពុករលួយនោះផង ប៉ុន្តែក៏មានកត្តាមួយចំនួន ដូចជា បទបញ្ញត្តិខាងពាណិជ្ជកម្ម និងគយ ជាដើម ដែលហាក់ដូចជាកាន់តែរាំងស្ទះខ្លាំងឡើង ។

---

៤ ធនាគារពិភពលោក (២០០៩) ការធ្វើឱ្យមានចីរភាពនូវកំណើនឆាប់រហ័សក្នុងបរិយាកាសដែលមានភាពប្រឈម អនុស្សារណៈសេដ្ឋកិច្ចប្រទេសកម្ពុជា ២០០៩ ។

# ជំរុញការនាំចេញអង្ករ របស់កម្ពុជា[១]

## សេចក្តីផ្តើម

សេដ្ឋកិច្ចកម្ពុជាកើនឡើងយ៉ាងលឿនក្នុងទសវត្សរ៍កន្លងទៅ ។ ពីឆ្នាំ១៩៩៨-២០០៨ ផសស របស់កម្ពុជា កើនបាន ៩,១% ក្នុងមួយឆ្នាំៗ ។ មានការមូលមតិថា កំណើនដ៏ខ្ពស់នេះ ជំរុញឡើងជាសំខាន់ដោយវិស័យ កាត់ដេរ សំណង់ និងទេសចរណ៍ ។ ទោះយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាភាគច្រើន នៅតែពឹងផ្អែកលើកសិកម្មនៅតាមទីជនបទនៅឡើយ ។ ទោះបីចំណែករបស់កសិកម្មក្នុង ផសស បានធ្លាក់ចុះជាបណ្តើរៗក្តី ក៏ក្នុងឆ្នាំ២០០៨ វានៅមានចំណែកដល់ ២៦% ក្នុង ផសស និងបានផ្តល់ការងារដល់ជាង ៥៦% នៃកំលាំងពលកម្មសរុបនៅកម្ពុជា ។ ប្រហែល ៨០% នៃប្រជាជនកម្ពុជាសព្វថ្ងៃរស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្ម ។

ជាមធ្យម វិស័យកសិកម្មមានកំណើនទាបជាង វិស័យឧស្សាហកម្ម និងសេវាកម្ម ។ ពីឆ្នាំ១៩៩៨-២០០៨ វិស័យកសិកម្មមានអត្រាកំណើនប្រមាណ ៤,២% ក្នុង១ឆ្នាំ ធៀបនឹង ៩,៩% សំរាប់វិស័យសេវាកម្ម និង ១៤,២% សំរាប់វិស័យឧស្សាហកម្ម ។ ក្នុងទសវត្សរ៍២០០០ កំណើនវិស័យកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំបានឡើងចុះមិនទៀងទាត់ជាខ្លាំង ហើយជួនកាលមានកំណើនអវិជ្ជមានទៀតផង ក្នុង ៥ឆ្នាំ ដើមទសវត្សរ៍២០០០ ប៉ុន្តែចាប់ពីឆ្នាំ២០០៥ មក វាមានកំណើនវិជ្ជមានជាប់រហូត ។ នៅឆ្នាំ២០០៩ កំណើនវិស័យកសិកម្ម មានប្រហែល ៥% ស្របពេលដែលកំណើនប៉ាន់ស្មាននៃ ផសស ស្ថិតនៅក្នុងចន្លោះពី -២,២% ដល់ +០,១% ។

ដោយសារមានអាកាសធាតុតំបន់ត្រូពិច សំបូរដីដាំដុះ និងមានកំលាំងពលកម្មគ្មានជំនាញច្រើន កម្ពុជាមានឧត្តមភាពក្នុងវិស័យកសិកម្ម ។ គេទទួលស្គាល់ជាទូទៅថា ការជំរុញវិស័យកសិកម្ម (កសិឧស្សាហកម្ម) ជាយុទ្ធសាស្ត្រល្អបំផុត សំរាប់ពង្រីកមូលដ្ឋានសេដ្ឋកិច្ច ទប់ទល់ការប៉ះទង្គិចខាងម៉ាក្រូសេដ្ឋកិច្ច ធានាសន្តិសុខស្បៀង កែលំអជីវភាពប្រជាជននៅតាមជនបទ និងកាត់បន្ថយភាពក្រីក្រ ។

ផលដំណាំមានចំណែកធំបំផុតក្នុងវិស័យកសិកម្ម បន្ទាប់មកគឺ ផលនេសាទ សត្វចិញ្ចឹម និងផលពីព្រៃឈើ ។ នៅឆ្នាំ២០០៨ ផលដំណាំមានចំណែក ៥៣% នៃផលិតផលកសិកម្ម ឬកើនឡើង ១២ឯកតាភាគរយ ធៀបនឹងឆ្នាំ១៩៩៨ (12 points more than in 1998) ហើយកំណើននេះ បានមួយផ្នែកមកពីការធ្លាក់ចុះនៃផលនេសាទ និងផលពីព្រៃឈើ ។ ផលិតផលកសិកម្មចំបងៗ គឺមាន ស្រូវ ពោត ដំឡូងឈើ សណ្តែកសៀង ថ្នាំជក់ និងកៅស៊ូ ។ ស្រូវអង្ករ ជាអាហារមូលដ្ឋាននៅកម្ពុជា និងមានចំណែកជាមធ្យម ៥៥%

១ លោក តុង គឹមស៊ុន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI បានពិនិត្យឡើងវិញ ពីការអភិវឌ្ឍកសិកម្មនៅកម្ពុជា ដោយផ្តោតលើផលិតកម្ម និងការនាំចេញស្រូវ ។ លោកឧកញ៉ា ភូ ពុយ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា បានផ្តល់ជាមតិយោបល់ ស្តីពីសក្តានុពលយ៉ាងច្រើនរបស់កម្ពុជាក្នុងការកិនស្រូវ និងនាំចេញអង្ករ ។

តារាង ១: ផលិតភាពស្រូវឆ្នាំ១៩៩៤-២០០៨ (តោន/ហិកតា)

| | ប្រ៊ុយណេ | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | ភូមា | ហ្វីលីពីន | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|---|
| 1994 | 1.67 | 1.49 | 4.35 | 2.58 | 3.06 | 3.17 | 2.89 | 2.35 | 3.57 |
| 1995 | 1.64 | 1.79 | 4.35 | 2.53 | 3.16 | 2.98 | 2.80 | 2.42 | 3.69 |
| 1996 | 1.65 | 1.81 | 4.42 | 2.55 | 3.25 | 3.06 | 2.86 | 2.41 | 3.77 |
| 1997 | 1.65 | 1.77 | 4.43 | 2.76 | 3.07 | 3.08 | 2.93 | 2.38 | 3.88 |
| 1998 | 1.65 | 1.79 | 4.20 | 2.71 | 2.88 | 3.13 | 2.70 | 2.47 | 3.96 |
| 1999 | 0.53 | 1.94 | 4.25 | 2.93 | 2.94 | 3.24 | 2.95 | 2.42 | 4.10 |
| 2000 | 0.65 | 2.12 | 4.40 | 3.06 | 3.06 | 3.38 | 3.07 | 2.61 | 4.24 |
| 2001 | 0.73 | 2.07 | 4.39 | 3.13 | 3.11 | 3.42 | 3.19 | 2.62 | 4.29 |
| 2002 | 0.73 | 1.92 | 4.47 | 3.27 | 3.24 | 3.42 | 3.28 | 2.61 | 4.59 |
| 2003 | 0.79 | 2.10 | 4.54 | 3.14 | 3.36 | 3.55 | 3.37 | 2.65 | 4.64 |
| 2004 | 0.82 | 1.98 | 4.54 | 3.28 | 3.33 | 3.79 | 3.51 | 2.86 | 4.86 |
| 2005 | 0.87 | 2.48 | 4.57 | 3.49 | 3.42 | 3.75 | 3.59 | 2.96 | 4.89 |
| 2006 | 1.22 | 2.49 | 4.62 | 3.35 | 3.39 | 3.80 | 3.68 | 2.92 | 4.89 |
| 2007 | 1.20 | 2.62 | 4.71 | 3.47 | 3.53 | 3.84 | 3.80 | 3.01 | 4.99 |
| 2008 | 1.20 | 2.75 | 4.89 | 3.47 | 3.57 | 3.72 | 3.77 | 2.97 | 5.22 |
| មធ្យមភាគ | 1.13 | 2.07 | 4.47 | 3.05 | 3.23 | 3.42 | 3.23 | 2.64 | 4.37 |
| អត្រាកំណើន | 1.67 | 4.84 | 0.88 | 2.21 | 1.16 | 1.20 | 2.00 | 1.73 | 2.78 |

*ប្រភព: FAO*